ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ: ២៩៧២ មស.សជណ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការចាក់វ៉ាក់សាំងកូវីដ-១៩ ជូនសមាជិកគ្រួសារអាយុចាប់ពី ១២ឆ្នាំ ដល់អាយុក្រោម១៨ឆ្នាំ របស់ថ្នាក់ដឹកនាំ និងមន្ត្រីថ្នាក់ជាតិនៃក្រសួងមុខងារសាធារណៈ

យោងសេចក្តីជូនព័ត៌មានលេខ៨៤៨/២១ គ.វ.ក-១៩ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២១ របស់គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស ស្តីពី យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ (ស៊ីណូវ៉ាក់) ដល់កុមារ និងយុវវ័យអាយុចាប់ពី១២ឆ្នាំ ដល់អាយុក្រោម១៨ឆ្នាំនៅរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តកោះកុង នោះ ក្រសួងមុខងារសាធារណៈ សូមជម្រាបជូនដំណឹងដល់ **ឯកឧត្តម លោកជំទាវ លោក លោកស្រីជាថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា** ថ្នាក់ជាតិរបស់ក្រសួង មេត្តាជ្រាបថា ការចាក់វ៉ាក់សាំងជូនដល់កុមារ និងយុវវ័យអាយុចាប់ពី១២ឆ្នាំ ដល់អាយុក្រោម១៨ឆ្នាំ ដែលជាបុត្រា បុត្រី និងអ្នកនៅក្រោមអាណាព្យាបាលដែលជាសមាជិកគ្រួសាររបស់ **ឯកឧត្តម លោកជំទាវ លោក លោកស្រី នឹងប្រព្រឹត្តទៅនៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១ ចាប់ពីម៉ោង ០៨:០០នាទី ដល់១១:០០នាទីព្រឹក និងចាប់ពីម៉ោង ១៤:០០នាទី ដល់១៧:០០នាទីសៀល នៅ៣ទីតាំង ដូចខាងក្រោម៖**

១. **មន្ទីរពេទ្យកាល់ម៉ែត** សម្រាប់ចាក់ជូនកូនចៅឥស្សរជនដែលមានតួនាទីជារដ្ឋមន្ត្រី រដ្ឋលេខាធិការ ឬមានឋានៈស្មើ

២. **នៅមន្ទីរពេទ្យព្រះអង្គឌួង** សម្រាប់ចាក់ជូនកូនចៅឥស្សរជនដែលជាអនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករង ឬមានឋានៈស្មើ

៣. **នៅមន្ទីរពេទ្យគន្ធបុប្ផាភ្នំពេញ(វត្តភ្នំ) មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក** សម្រាប់ចាក់ជូនកូនចៅឥស្សរជនដែលមានតួនាទីជាប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ អនុប្រធានការិយាល័យ បុគ្គលិកក្របខ័ណ្ឌ និងមន្ត្រីជាប់កិច្ចសន្យា

ក្រៅពីនេះ **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ក៏អាចនាំកូនចៅទៅចាក់វ៉ាក់សាំងនេះនៅក្រោមកម្មវិធីចាក់វ៉ាក់សាំងកូវីដ-១៩របស់អាជ្ញាធរមូលដ្ឋានផងដែរ។

ដើម្បីជួយឲ្យកិច្ចការនេះប្រព្រឹត្តទៅដោយរលូន សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី សហការចូលរួមដូចខាងក្រោម៖**

១. ផ្តល់ឈ្មោះ និងអាយុសមាជិកគ្រួសារដែលមានអាយុចាប់ពី១២ឆ្នាំ ដល់១៨ឆ្នាំទៅអគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពថ្នាក់ស្មើទាំងអស់របស់ **ឯកឧត្តម លោកជំទាវ លោក លោកស្រី**។ នាយកដ្ឋានរដ្ឋបាលនិងសរុបនឹងទទួលបញ្ជី



ផ្លូវវិថីតាមអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

នោះជាច្បាប់ដើមដើម្បីបញ្ជូនទៅទីតាំងចាក់វ៉ាក់សាំងដែលបានកំណត់។ នាយកដ្ឋានគ្រប់គ្រងបុគ្គលិកនឹងទទួលបញ្ជីឈ្មោះជាឯកសារទន់ដើម្បីធ្វើការសរុបរួម។

២. យកជាមួយទៅកន្លែងចាក់វ៉ាក់សាំងនូវឯកសារបញ្ជាក់ពីភាពជាសមាជិកគ្រួសាររបស់ **ឯកឧត្តម លោកជំទាវ លោក លោកស្រី** នៃអ្នកដែលត្រូវចាក់វ៉ាក់សាំង ដូចជា សំបុត្រកំណើត សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ ឬលិខិតឆ្លងដែន និងអត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួន។

ក្នុងគោលដៅកសាងភាពស៊ាំរបស់ក្រសួងមុខងារសាធារណៈ ក៏ដូចជាចូលរួមកសាងភាពស៊ាំរបស់សហគមន៍ ទប់ទល់នឹងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជាមាតាបិតា និងអាណាព្យាបាល នាំកូនចៅដែលជាកុមារ និងយុវវ័យអាយុចាប់ពី១២ឆ្នាំ ដល់អាយុក្រោម១៨ឆ្នាំទាំងអស់ទៅចាក់វ៉ាក់សាំងកូវីដ-១៩ឲ្យបានគ្រប់ៗគ្នា។ ក្រោយយុទ្ធនាការ ចាក់វ៉ាក់សាំងនេះ សូម **ឯកឧត្តមអគ្គនាយក អគ្គាធិការ នាយកសាលាភូមិន្ទរដ្ឋបាល និងប្រធានអង្គភាពថ្នាក់ស្មើទាំងអស់** ផ្តល់ព័ត៌មានពីចំនួនសមាជិកគ្រួសារ អាយុចាប់ពី១២ឆ្នាំឡើង បានចាក់ និងមិនបានចាក់វ៉ាក់សាំងកូវីដ-១៩ សរុបតាមនាយកដ្ឋាន ឲ្យបានមុនថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១ ទៅនាយកដ្ឋានគ្រប់គ្រងបុគ្គលិកដើម្បីធ្វើការសរុបរួម។

អាស្រ័យដូចជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាមាតាបិតា និងអាណាព្យាបាល** ទាំងអស់អនុវត្តតាមការជូនដំណឹងខាងលើប្រកបដោយការទទួលខុសត្រូវខ្ពស់។

ថ្ងៃ ចន្ទ ៩រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ សីហា ឆ្នាំ២០២១

**រដ្ឋលេខាធិការ**

**ប្រធានអនុគណៈកម្មការចាក់វ៉ាក់សាំងកូវីដ-១៩**

**របស់ក្រសួងមុខងារសាធារណៈ**

**អែម ប៊ុនថុល**